# អ្នកសំខាន់ចំពោះទ្រង់

*ដោយប្រធាន ឌៀថើរ អេហ្វ អុជដូហ្វ*
*ទីប្រឹក្សាទីពីរនៅ ក្នុងគណៈប្រធានទីមួយ*

ម៉ូសេ ជាព្យាការីដ៏អស្ចារ្យមួយរូប ដែលពិភពលោកស្គាល់ គាត់ត្រូវបានកូនស្រីរបស់ផារ៉ោនចិញ្ចឹម ហើយបានចំណាយរយៈពេល40 ឆ្នាំដំបូងនៃជីវិតរបស់គាត់ នៅក្នុងរាជវាំងអេស៊ីព្ទ ។ គាត់បានដឹងដោយផ្ទាល់អំពីសិរីល្អ និងភាពអស្ចារ្យនៃនគរបុរាណនោះ ។ ជាច្រើនឆ្នាំក្រោយមក ម៉ូសេបានឈរនៅក្នុងវត្តមានរបស់ព្រះ ហើយបានទូលទៅកាន់ទ្រង់ប្រទល់មុខ ដូចជាមនុស្សម្នាក់និយាយជាមួយមិត្តភក្តិខ្លួន នៅលើកំពូលភ្នំដាច់ស្រយាល នៅឆ្ងាយពីអណាចក្រអេស៊ីព្ទដ៏សប្បូរណ៍ រុងរឿង ។[1]

អំឡុងពេលនៃការជួបនោះ ព្រះបានបង្ហាញម៉ូសេអំពីផលនៃព្រះហស្តទ្រង់ បានឲ្យគាត់មើលឃើញអំពីកិច្ចការ និងសិរីល្អរបស់ទ្រង់ ។ នៅពេលការនិមិត្តបានបញ្ចប់ ម៉ូសេបានដួលទៅលើដីអស់រយៈពេលជាច្រើនម៉ោង ។ នៅពេលគាត់បានទទួលកម្លាំងគាត់ត្រឡប់មកវិញ គាត់បានដឹងនូវអ្វីមួយដែលពុំធ្លាប់កើតមានចំពោះគាត់កាលពីមុន ពេលនៅក្នុងរាជវាំងរបស់ផារ៉ោនជាច្រើនឆ្នាំមកនោះ ។ គាត់បាននិយាយថា « ខ្ញុំដឹងថា មនុស្សគឺគ្មានជាអ្វីសោះ » ។[2]

## យើងតូចទាបជាងយើងគិតស្មានទៅទៀត

កាលណាយើងកាន់តែរៀនអំពីសាកលលោក នោះយើងកាន់តែយល់--- យ៉ាងហោចណាស់នៅក្នុងចំណុចតូចមួយ--- ពីអ្វីដែលម៉ូសេបានដឹង ។ សាកលលោកធំធេង អាថិកំបាំង ហើយរុងរឿងណាស់ ដែលគំនិតមនុស្សពុំអាចយល់ ។ ព្រះមានបន្ទូលទៅម៉ូសេថា « ពិភពលោកដ៏ច្រើនឥតគណនា នោះយើងបានបង្កើតឡើង » ។[3] ផ្ទៃមេឃនារាត្រីដ៏អស្ចារ្យ គឺជាទីបន្ទាល់ដ៏ស្រស់ស្អាតនៃសេចក្តីពិតនោះ ។

មានរឿងមួយចំនួនដែលធ្វើឲ្យខ្ញុំអស្ចារ្យស្ទើរតែពុំដង្ហើម ពេលខ្ញុំហោះហើរនៅពេលយប់ងងឹតឆ្លងកាត់មហាសមុទ្រ និងទ្វីបជាច្រើន ហើយមើលទៅផ្កាយរាប់លានដ៏រុងរឿងគ្មានដែនកំណត់តាមមាត់បង្អួចកាប៊ីនយន្តហោះរបស់ខ្ញុំ ។

ពួកតារាវិទូចង់រាប់ចំនួនផ្កាយនៅក្នុងសាកលលោក ។ អ្នកវិទ្យាសាស្រ្តមួយក្រុមបានប៉ាន់ស្មានថា ចំនួនផ្កាយនៅក្នុងរង្វង់នៃកែវយឺតរបស់យើង គឺមានចំនួន 10 ដងច្រើនជាងគ្រាប់ខ្សាច់ទាំងអស់នៅលើឆ្នេរខ្សាច់ និង វាលខ្សាច់នៃពិភពលោកនេះទៅទៀត ។[4]

ការសន្និដ្ឋាននេះ គឺមានភាពស្រដៀងគ្នាមួយទៅនឹងការអះអាងរបស់ព្យាការីហេណុកពីបុរាណថា ៖ « ហើយទោះបីជាមនុស្សអាចរាប់ចុណ្ណភាគទាំងឡាយនៃផែនដី មែនហើយគឺផែនដីរាប់លាន ដូចជាផែនដីនេះ គង់តែពុំមែនជាការចាប់ផ្តើមនូវចំនួននៃការបង្កបង្កើតរបស់ទ្រង់ដែរ » ។[5]
នៅពេលយើងគិតអំពីភាពធំធេងនៃការបង្កបង្កើតរបស់ព្រះ នោះគ្មានអ្វីដែលយើងងឿងឆ្ងល់អំពីស្តេចបេនយ៉ាមីនដ៏មហិមា ទូន្មានដល់ប្រជាជនគាត់ថា « ចងចាំជានិច្ចនូវភាពមហិមានៃព្រះ និងភាពឥតន័យរបស់អ្នក » នោះឡើយ ។[6]

## យើងមហិមាជាងយើងគិតស្មានដល់

ទោះបីជាមនុស្សគឺគ្មានជាអ្វីសោះក៏ដោយ វាធ្វើឲ្យខ្ញុំអស្ចារ្យ និងស្ងើចសរសើរ ពេលគិតថា « តម្លៃនៃព្រលឹងទាំងឡាយ គឺមហិមាណាស់ចំពោះព្រះនេត្រនៃព្រះ » ។[7]

ហើយនៅពេលយើងមើលទៅសាកលលោកដ៏ធំធេង ហើយនិយាយថា « តើមនុស្សដូចជាអ្វីបើប្រៀបធៀបទៅនឹងសិរីល្អនៃការបង្កបង្កើត ? » ព្រះបានមានបន្ទូលថា យើងជាមូលហេតុដែលទ្រង់បានបង្កើតសាកលលោកនេះ ! កិច្ចការ និង សិរីល្អរបស់ទ្រង់ --- គោលបំណងនៃសាកលលោកដ៏រុងរឿងនេះ ---គឺសង្គ្រោះ និងតម្កើងដល់មនុស្ស ។[8] ម្យ៉ាងទៀត ភាពធំធេងនៃភាពអស់កល្បជានិច្ច សិរីល្អ និងអាថិកំបាំងនៃអវកាសគ្មានព្រំដែននេះ និងពេលវេលាទាំងអស់នេះបង្កើតឡើង សម្រាប់ជាប្រយោជន៍នៃជីវិតរមែងស្លាប់ ដូចជាអ្នក និងខ្ញុំ ។ ព្រះវរបិតាសួគ៌របស់យើង បានបង្កើតសាកលលោកដើម្បីឲ្យយើងអាចនឹងឈោងទៅដល់សក្តានុពលរបស់យើង ជាបុត្រា និង បុត្រីរបស់ទ្រង់ ។

នេះគឺជាមតិផ្ទុយមួយរបស់មនុស្ស ៖ បើប្រៀបនឹងព្រះ មនុស្សគឺគ្មានជាអ្វីសោះ ប៉ុន្តែយើងគឺជាអ្វីៗទាំងអស់ចំពោះព្រះ ។ នៅពេលប្រៀបធៀបទៅនឹងការបង្កបង្កើតដ៏គ្មានព្រំដែន នោះយើងគឺគ្មានជាអ្វីសោះ យើងមានពន្លឺភ្លើងដ៏អស់កល្បជានិច្ចឆេះឆួលនៅក្នុងខ្លួនយើង ។ យើងមានការសន្យាដែលពុំ

អាចយល់បាននៃភាពតម្កើងឡើង --- ពិភពលោកគ្មានទីបញ្ចប់ --- នៅក្នុងកណ្តាប់ដៃរបស់យើង ។ ហើយនោះ គឺជាបំណង ព្រះទ័យដ៏មហិមារបស់ព្រះ ដើម្បីជួយយើងឲ្យទទួលបានវា ។

**ភាពល្វីល្វើនៃអំណួត**

មេល្បួងដឹងថាឧបករណ៍ដ៏មានប្រសិទ្ធភាពបំផុតមួយរបស់វា នៅក្នុងការដឹកនាំកូនចៅរបស់ព្រះឲ្យវង្វេង គឺទាញឲ្យទៅរកភាពលើសលប់នៃមតិផ្ទុយរបស់មនុស្ស ។ ចំពោះមនុស្សមួយចំនួន វាទាញឲ្យទៅរកទំនោរប្រកបដោយអំណួត បំប៉ោងពួកគេឡើង ហើយបញ្ឆោពួកគេឲ្យជឿទៅលើសុបិននៃភាពសំខាន់តែខ្លួនឯង និងភាពចេះមិនចុះចាញ់ផ្ទាល់ខ្លួនរបស់ពួកគេ ។ វាប្រាប់ពួកគេថា ពួកគេមានអ្វីហួសពីធម្មតា ហើយនោះដោយសារតែសមត្ថភាព សិទ្ធិពីកំណើត ឬស្ថានភាពសង្គម ដែលពួកគេមានល្អប្រសើរជាងអ្វីៗផ្សេងទៀតដែលមានសមត្ថភាពជាទូទៅនៅជុំវិញពួកគេ ។ វាដឹកនាំពួកគេឲ្យសន្និដ្ឋានថា ពួកគេពុំស្ថិតនៅក្រោមច្បាប់របស់មនុស្សណាម្នាក់ទេ ហើយពុំរវីរវល់នឹងបញ្ហារបស់អ្នកដទៃណាឡើយ ។ គឺត្រូវគេបានអះអាងថា អ័ប្រាហាំ ឡីងគិន បានស្រឡាញ់កំណាព្យដែលសរសេរថា ៖

*ឱ តើហេតុអ្វីបានជាវិញ្ញាណនៃមនុស្សរមែងស្លាប់មានអំណួត?*
*ដូចជា អាកាសបាតុគ្គតដើរយ៉ាងរហ័ស ពពកហោះយ៉ាងលឿន*
*ពន្លឺផ្លេកបន្ទោរចាំងព្រាកៗ បំបែកទឹករលក*
*មនុស្សចាកស្ថាន ទៅសម្រាកនៅក្នុងផ្នូ ។*[9]

ពួកសិស្សនៃព្រះយេស៊ូវគ្រីស្ទយល់អំពីការប្រៀបធៀបទៅនឹងភាពអស់កល្បនោះ ជីវិតរបស់យើងនៅក្នុងដែនជីវិតរមែងស្លាប់នេះ គឺ « គ្រាន់តែមួយភ្លែត » ប៉ុណ្ណោះ នៅក្នុងលំហរ និងពេលវេលា ។[10]

ពួកគេដឹងថា តម្លៃពិតរបស់មនុស្សម្នាក់ ពុំមានអ្វីទាក់ទងនឹងការគោរពខ្ពង់ខ្ពស់របស់លោកិយទេ ។ ពួកគេដឹងថា អ្នកអាចប្រមូលប្រាក់ទាំងអស់ក្នុងពិភពលោកទាំងមូលមក តែវាមិនអាចទិញនំប៉័ងមួយដុំក្នុងសេដ្ឋកិច្ចស្ថានសួគ៌បានទេ ។

អ្នកទាំងឡាយណាដែលនឹង « គ្រងនគរព្រះ » [11] គឺជាអ្នកដែលក្លាយជា « កូនក្មេង ងាយប្រដៅ ស្លូតបូត ទាបរាបសា អត់ឱន ពោរពេញទៅដោយសេចក្តីស្រឡាញ់ » ។ [12] « ត្បិតអស់អ្នកណាដែលតម្កើងខ្លួន នោះនឹងត្រូវបន្ទាបវិញ ហើយអ្នកណាដែលបន្ទាបខ្លួន នោះនឹងបានតម្កើងឡើង » ។ [13] ពួកសិស្សទាំងនោះយល់ផងដែរ « ថា កាលណាអ្នករាល់គ្នានៅក្នុងការបម្រើដល់មនុស្សទូទៅ នោះអ្នករាល់គ្នាគ្រាន់តែនៅក្នុងការបម្រើដល់ព្រះរបស់អ្នកតែប៉ុណ្ណោះ » ។ [14]

**យើងពុំត្រូវបានបំភ្លេចឡើយ**

វិធីមួយទៀតដែលសាតាំងបញ្ឆោត គឺតាមរយៈការបំបាក់ទឹកចិត្ត ។ វាប៉ុនប៉ងឲ្យយើងមើលទៅលើភាពមិនសំខាន់ផ្ទាល់ខ្លួនរបស់យើង រហូតទាល់តែយើងចាប់ផ្តើមសង្ស័យថា យើងមានពុំសូវមានតម្លៃឡើយ ។ វាប្រាប់យើងថា យើងពុំសូវមានគេកត់សំគាល់ទេ ថាយើងត្រូវបានគេបំភ្លេចចោល --- ជាពិសេសព្រះ។

ខ្ញុំសូមចែកចាយជាមួយអ្នកនូវបទពិសោធន៍ផ្ទាល់ខ្លួនមួយ ដែលវាអាចនឹងជាជំនួយខ្លះៗ ដល់អ្នកទាំងឡាយ ដែលមានអារម្មណ៍ពុំសំខាន់ ត្រូវបានគេបំភ្លេច ឬ ឯកោ ។

ជាច្រើនឆ្នាំកន្លងទៅ ខ្ញុំបានចូលហ្វឹកហាត់រៀនធ្វើជាអ្នកបើកយន្តហោះ នៅក្នុងកងទ័ពអាកាសសហរដ្ឋ ។ ខ្ញុំនៅឆ្ងាយពីផ្ទះ ជាទាហានអាល្លឺម៉ង់ប៉ែកខាងលិចវ័យក្មេងម្នាក់ កើតនៅឆេកូស្លូវ៉ាគី បានធំឡើងនៅអាល្លឺម៉ង់ខាងកើត ហើយនិយាយភាសាអង់គ្លេសយ៉ាងលំបាក ។ ខ្ញុំចាំយ៉ាងច្បាស់អំពីការធ្វើដំណើររបស់ខ្ញុំទៅកាន់មូលដ្ឋានហ្វឹកហាត់នៅរដ្ឋតិចសាស ។ ខ្ញុំជិះលើយន្តហោះ អង្គុយជិតនឹងអ្នកធ្វើដំណើរមួយរូប ដែលនិយាយសំនៀងអ្នកនៅប៉ែកខាងត្បូង ។ ខ្ញុំពិបាកស្តាប់យល់ពាក្យដែលគាត់បាននិយាយ ។ ប្រាកដណាស់ ខ្ញុំបានងឿងឆ្ងល់ថា តើខ្ញុំបានរៀនភាសាខុសទេដឹង ។ ខ្ញុំបានភ័យពេលគិតថា ខ្ញុំត្រូវប្រកួតប្រជែងយកកន្លែងខ្ពស់ជាងគេ នៅក្នុងការហ្វឹកហាត់ជាអ្នកបើកយន្តហោះ ជាមួយនឹងសិស្សដែលជាអ្នកនិយាយភាសាអង់គ្លេសដើមកំណើត ។

នៅពេលខ្ញុំទៅដល់មូលដ្ឋានទ័ពអាកាសនៅក្នុងក្រុងប៊ីគស្ព្រីង តូចមួយ ក្នុងរដ្ឋតិចសាស ខ្ញុំបានរកមើល ហើយឃើញមានសាខាពួកបរិសុទ្ធថ្ងៃចុងក្រោយ ដែលមានសមាជិកដ៏ល្អៗមួយក្រុម ដែលជួបប្រជុំនៅបន្ទប់ជួលក្នុងមូលដ្ឋានទ័ពអាកាស ។ សមាជិកទាំងឡាយកំពុងតែសាងសង់អគារប្រជុំតូចមួយ ដែលនឹងជាកន្លែងអចិន្ត្រៃយ៍សម្រាប់ព្រះវិហារ ។ កាលពីជំនាន់នោះ សមាជិកជួយធ្វើការនៅក្នុងការសង់អគារថ្មីៗជាច្រើន ។

ពីមួយថ្ងៃទៅមួយថ្ងៃ ខ្ញុំចូលរួមនៅក្នុងការហ្វឹកហាត់ជាអ្នកបើកយន្តហោះ ហើយខំសិក្សាយ៉ាងខ្លាំងអស់ពីសមត្ថភាព ហើយចំណាយពេលទំនេររបស់ខ្ញុំភាគច្រើនជួយធ្វើការសាងសង់អគារប្រជុំថ្មីនោះ ។ នៅទីនោះ ខ្ញុំបានដឹងថា បន្ទះឈើទំហំពីរនឹងបួន ពុំមែនជាជំហានរាំទេ ប៉ុន្តែជាកំណាត់ឈើ ។ ខ្ញុំក៏រៀនជំនាញដំដែកគោលដ៏សំខាន់ កុំឲ្យត្រូវមេដៃផងដែរ ។

ខ្ញុំបានចំណាយពេលយ៉ាងច្រើនធ្វើការសាងសង់អគារអាគារប្រជុំ ដែលប្រធានសាខា--- ជាគ្រូបង្រៀនបើកយន្តហោះម្នាក់របស់យើងផងដែរ --- គាត់បានបង្ហាញអំពីការព្រួយបារម្ភថា ខ្ញុំគួរតែចំណាយពេលសិក្សាឲ្យបានច្រើន ។

មិត្តភក្តិរបស់ខ្ញុំ និង បងប្អូន និសិត្សអ្នកបើកយន្តហោះរបស់ខ្ញុំ បានចូលរួមនៅក្នុងសកម្មភាពពេលទំនេរទាំងឡាយផងដែរ ទោះជាខ្ញុំដឹងថា វាពុំល្អដែលនិយាយថា សកម្មភាពទាំងនោះមួយចំនួនពុំស្របទៅនឹងសកម្មភាពក្នុងកូនសៀវភៅ *ដើម្បីកម្លាំងនៃយុវជន* សព្វថ្ងៃនេះក្តី ។ សម្រាប់ខ្លួនខ្ញុំ ខ្ញុំពេញចិត្តនឹង រួមចំណែកដ៏សកម្មនៅក្នុងសាខា តិចសាស ខាងលិចដ៏តូចនេះ ហាត់ជំនាញជាងឈើថ្មីរបស់ខ្ញុំ និងអភិវឌ្ឍភាសាអង់គ្លេសរបស់ខ្ញុំ នៅពេលខ្ញុំបំពេញការហៅបម្រើរបស់ខ្ញុំ ដើម្បីបង្រៀនដល់កូរ៉ុមអែលឌើរ និងថ្នាក់សាលាថ្ងៃអាទិត្យ ។

ស្របពេលនោះប៊ីគស្ព្រីង ថ្វីបើជាឈ្មោះរបស់វា គឺជាកន្លែងតូច ពុំសំខាន់ និងគេពុំដែលស្គាល់ ។ ជាញឹកញាប់ ខ្ញុំមានអារម្មណ៍ដូចគ្នានេះអំពីខ្លួនខ្ញុំ ថាខ្ញុំ --- ពុំសំខាន់ គ្មានគេស្គាល់ និង នៅឯកោ ។ ទោះជាយ៉ាងនោះក្តី  ខ្ញុំពុំដែលងឿងឆ្ងល់ថា ព្រះភ្លេចខ្ញុំ ឬថាព្រះរកខ្ញុំនៅទីនោះពុំឃើញនោះទេ ។ ខ្ញុំដឹងថា វាពុំសំខាន់ថាខ្ញុំនៅកន្លែងណា ខ្ញុំមានឋានៈណាជាមួយអ្នកដទៃ នៅក្នុងថ្នាក់ហ្វឹកហាត់អ្នកបើកយន្តហោះរបស់ខ្ញុំ ឬ ការហៅនៅក្នុងសាសនាចក្ររបស់ខ្ញុំជាអ្វី ចំពោះព្រះវរបិតាសួគ៌នោះទេ ។ អ្វីដែលសំខាន់ចំពោះទ្រង់គឺថា ខ្ញុំកំពុងខំអស់ពីលទ្ធភាពរបស់ខ្ញុំថា ខ្ញុំស្រឡាញ់ទ្រង់ ហើយថាខ្ញុំមានឆន្ទៈជួយដល់អ្នកនៅជុំវិញខ្ញុំ ។ ខ្ញុំដឹងបើខ្ញុំបានធ្វើអស់ពីលទ្ធភាពនោះអ្វីៗនឹងបានល្អ ។ ហើយអ្វីៗគឺបានល្អហើយ ។

**អ្នកក្រោយនឹងទៅជាមុន**

ព្រះអម្ចាស់ពុំខ្វល់ថា យើងចំណាយពេលមួយជីវិតធ្វើការនៅក្នុងសាលថ្មកែវ ឬក្រោលសត្វនោះឡើយ ។ ទ្រង់ដឹងថាយើងនៅកន្លែងណា មិនថាយើងស្ថិតនៅក្នុងកាលៈទេសៈយ៉ាងណាឡើយ ។ ទ្រង់នឹងប្រើ --- តាមរបៀបរបស់ទ្រង់ផ្ទាល់ និងសម្រាប់គោលបំណងដ៏បរិសុទ្ធរបស់ទ្រង់ --- អ្នកទាំងឡាយដែលស្រឡាញ់ទ្រង់ ។

ព្រះដឹងថា មានព្រលឹងដ៏មហិមាមួយចំនួន ដែលបានរស់នៅ គឺជាអ្នកទាំងឡាយ ដែលពុំដែលមានកត់ត្រានៅក្នុងប្រវត្តិសាស្រ្ត ។ ពួកគេគឺជាព្រលឹងមានពរ និងរាបសារ ដែលធ្វើតាមគំរូព្រះអង្គសង្គ្រោះ ហើយចំណាយពេលក្នុងជីវិតរបស់ពួកគេធ្វើទង្វើល្អ ។ [15]

មានគូស្វាមីភរិយាមួយគូប្រភេទនោះ ដែលជាឪពុកម្តាយរបស់មិត្តភក្តិម្នាក់របស់ខ្ញុំ មានគំរូល្អអំពីគោលការណ៍នេះចំពោះខ្ញុំ ។ ប្តីធ្វើការនៅក្នុងរោងចក្រដែកថែបក្នុងរដ្ឋយូថាហ៍ ។ ពេលបាយថ្ងៃត្រង់ គាត់នឹងទាញគម្ពីរ ឬ ទស្សនាវដ្តីសាសនាចក្ររបស់គាត់ចេញមកអាន ។  នៅពេលអ្នកធ្វើការដទៃទៀតមើលឃើញដូច្នេះ ពួកគេចំអកដល់គាត់ ហើយសាកល្បងជំនឿរបស់គាត់ ។ នៅពេលណាពួកគេបានធ្វើដូច្នោះ គាត់និយាយទៅកាន់ពួកគេដោយសន្តានចិត្តល្អ និងមានទំនុកចិត្ត ។ គាត់ពុំអនុញ្ញាតឲ្យការពុំគោរពរបស់ពួកគេមកធ្វើឲ្យគាត់ខឹង ឬអន់ចិត្តឡើយ ។

ជាច្រើនឆ្នាំក្រោយមក អ្នកចំអកខ្លាំងជាងគេម្នាក់បានឈឺ។ មុនពេលគាត់ស្លាប់ គាត់បានស្នើសុំឲ្យបុរសរាបសារនេះ និយាយនៅក្នុងបុណ្យសពរបស់គាត់ --- បុរសនេះក៏បាននិយាយតាមសំណើរ ។

សមាជិកនៃសាសនាចក្រស្មោះត្រង់នេះ ពុំមានឋានៈក្នុងសង្គម ឬទ្រព្យសម្បត្តិច្រើនទេ ប៉ុន្តែគាត់មានឥទ្ធិពលយ៉ាងខ្លាំងដល់មនុស្សទាំងអស់ដែលស្គាល់គាត់ ។  គាត់បានទទួលមរណភាពនៅក្នុងឧប្បទ្ទវហេតុខាងឧស្សាហកម្ម ខណៈពេលឈប់ទៅជួយដល់អ្នកធ្វើការផ្សេងទៀត ដែលបានឈរនៅក្នុងទឹកកក ។

ក្នុងរយៈពេលមួយឆ្នាំ ប្រពន្ធមេម៉ាយរបស់គាត់ ត្រូវទទួលការវះកាត់ខួរក្បាល ដែលបានធ្វើឲ្យគាត់ដើរពុំរួច ។ ប៉ុន្តែមនុស្សចូលចិត្តមកចំណាយពេលជាមួយគាត់ ដោយសារគាត់ស្តាប់ ។ គាត់ចងចាំ ។ គាត់យកចិត្តទុកដាក់ ។ ដោយសារគាត់ពុំអាចសរសេរ នោះគាត់ទន្ទេញចាំលេខទូរស័ព្ទកូន និងចៅៗរបស់គាត់ ។ គាត់ចងចាំថ្ងៃខួបកំណើត និងបុណ្យខួបនានាដោយក្តីស្រឡាញ់ ។

អស់អ្នកដែលមកសួរសុខទុក្ខគាត់ ចេញទៅវិញដោយមានអារម្មណ៍ល្អអំពីជីវិត និងខ្លួនគេផ្ទាល់ ។ ពួកគេដឹងពីក្តីស្រឡាញ់របស់គាត់ ។ ពួកគេដឹងថាគាត់យកចិត្តទុកដាក់ ។ គាត់ពុំដែលរអ៊ូរទាំ ប៉ុន្តែចំណាយពេលក្នុងជីវិតរបស់គាត់ ប្រទានពរដល់ជីវិតមនុស្សដទៃ ។ មិត្តម្នាក់របស់គាត់បាននិយាយថា ស្ត្រីនេះគឺជាមនុស្សមួយរូបក្នុងចំណោមមនុស្សមួយចំនួនតូច ដែលគាត់បានស្គាល់ ដែលបានធ្វើជាគំរូពិតនៃក្តីស្រឡាញ់ និងជីវិតរបស់ព្រះយេស៊ូវគ្រីស្ទ ។

គូស្វាមីភរិយានេះ នឹងជាមនុស្សមុនគេដើម្បីនិយាយថា ពួកគេពុំសូវសំខាន់នៅក្នុងលោកិយនេះទេ ។ ប៉ុន្តែព្រះអម្ចាស់ ប្រើការថ្លឹងថ្លែងខុសគ្នាទាំងស្រុងពីការថ្លឹងថ្លែងរបស់លោកិយ អំពីតម្លៃនៃព្រលឹង ។ ទ្រង់ស្គាល់គូស្វាមីភរិយាស្មោះត្រង់នេះ ទ្រង់ស្រឡាញ់ពួកគេ ។ សកម្មភាពទាំងឡាយរបស់ពួកគេ គឺជាសាក្សីរស់រវើកអំពីសេចក្តីជំនឿរឹងមាំរបស់ពួកគេទៅលើទ្រង់ ។

**អ្នកសំខាន់**

បងប្អូនប្រុសស្រី វាជាការពិត ដែលមនុស្សគឺគ្មានជាអ្វីសោះបើប្រៀបទៅនឹងភាពធំធេងនៃសាកលលោក ។ ជួនកាលយើងអាចមានអារម្មណ៍ពុំសំខាន់ គ្មានគេកត់សំគាល់ ឯកោ ឬត្រូវបានគេបំភ្លេច ។ ប៉ុន្តែសូមចងចាំជានិច្ចថា --- អ្នកសំខាន់ចំពោះទ្រង់ ! បើសិនជាអ្នកសង្ស័យ ចូរពិចារណានូវគោលការណ៍ដ៏ទេវភាពទាំងបួននេះ ៖

ទីមួយ ព្រះស្រឡាញ់មនុស្សក្រខ្សត់ ហើយរាបសារ ត្បិតពួកគេ « ជាអ្នកធំជាងគេក្នុងនគរស្ថានសួគ៌ហើយ » ។ [16]

ទីពីរ ព្រះអម្ចាស់ទុកចិត្តឲ្យ« ភាពពោរពេញនៃដំណឹងល្អ [របស់ទ្រង់ ] អាចបានប្រាប់ [ដោយ] ពួកកំសោយ និងពួករាបទាប ដល់អស់ចុងផែនដី » ។ [17] ទ្រង់បានជ្រើសរើស « ពួកកំសោយនៅពិភពលោក [ឲ្យ] ចេញមក ហើយទម្លាក់ពួកខ្លាំងពូកែចុះ » [18] ហើយដាក់ឲ្យ « អ្នកប្រាជ្ញមានសេចក្តីខ្មាស់វិញ » ។ [19]

ទីបី មិនថាអ្នករស់នៅកន្លែងណា ស្ថានភាពរបស់អ្នកទន់ទាបយ៉ាងណា ការងាររបស់អ្នកអន់យ៉ាងណា សមត្ថភាពអ្នកមានកំរិតណា រូបរាងអ្នកសាមញ្ញយ៉ាងណា ឬការហៅក្នុងសាសនាចក្ររបស់អ្នកតិចតួចយ៉ាងណាទេ ព្រះវរបិតាសួគ៌របស់អ្នកទ្រង់ទតឃើញអ្នក ។ ទ្រង់ស្រឡាញ់អ្នក ។ ទ្រង់ស្គាល់ដួងចិត្តទន់ទាបរបស់អ្នក និងទង្វើនៃក្តីស្រឡាញ់ និងដួងចិត្តល្អរបស់អ្នក ។ វាទាំងអស់នេះ បង្កើតបានជាទីបន្ទាល់យូរអង្វែងអំពីភក្តីភាព និងសេចក្តីជំនឿរបស់អ្នក ។

ទីបួន និង ជាទីបញ្ចប់ សូមយល់ថា អ្វីដែលអ្នកមើលឃើញ និង ជួបប្រទះឥឡូវនេះ ពុំមែនជាអ្វីនឹងឋិតយូរអង្វែងឡើយ ។ អ្នកនឹងពុំមានអារម្មណ៍ឯកោ សោកសៅ ឈឺចាប់ ឬបាក់ទឹកចិត្តជារៀងរហូតទេ ។ យើងមានការសន្យាដ៏ស្មោះត្រង់ពីព្រះថា ទ្រង់នឹងពុំដែលភ្លេច ឬបោះបង់ចោលអ្នកទាំងឡាយដែលស្រឡាញ់ទ្រង់ឡើយ ។ [20] ចូរមានសេចក្តីសង្ឃឹម និងសេចក្តីជំនឿទៅលើការសន្យានោះ ។ ចូររៀនស្រឡាញ់ព្រះវរបិតាសួគ៌អ្នក ហើយក្លាយជាសិស្សរបស់ទ្រង់ទាំងពាក្យសម្តី និងទង្វើ ។

ត្រូវប្រាកដថា បើអ្នកនឹងគ្រាន់តែប្រកាន់ខ្ជាប់ ជឿទៅលើទ្រង់ ហើយនៅស្មោះត្រង់ នៅក្នុងការរក្សាព្រះបញ្ញត្តិ នោះនៅថ្ងៃមួយ អ្នកនឹងមានបទពិសោធន៍ផ្ទាល់ខ្លួន នូវការសន្យាទាំងឡាយ ដែលបានបើកសម្តែងដល់សាវកប៉ុលថា ៖ « សេចក្តីដែលភ្នែកមិនដែលឃើញ ត្រចៀកមិនដែលឮ ហើយចិត្តនឹកមិនដែលដល់ គឺសេចក្តីនោះឯងដែលព្រះបានរៀបចំទុក សម្រាប់ពួកអ្នកដែលស្រឡាញ់ទ្រង់ » ។ [21]

បងប្អូនប្រុសស្រី អង្គដែលមានព្រះចេស្តាបំផុតនៅក្នុងសាកលលោក គឺជាព្រះបិតានៃវិញ្ញាណរបស់អ្នក ។ ទ្រង់ស្គាល់អ្នក ។ ទ្រង់ស្រឡាញ់អ្នកដោយក្តីស្រឡាញ់ដ៏ឥតខ្ចោះ ។

ព្រះទតមើលអ្នកពុំមែនតែជាមនុស្សរមែងស្លាប់នៅក្នុងភពតូចមួយ ដែលយើងរស់នៅមួយរយៈនេះនោះទេ--- ទ្រង់ទតមើលអ្នកជាបុត្ររបស់ទ្រង់ ។ ទ្រង់ទតមើលអ្នកជាអង្គ ដែលអ្នកមានសមត្ថភាព និង បានគ្រោងដើម្បីប្រែក្លាយ ។ ទ្រង់ចង់ឲ្យអ្នកដឹងថាអ្នកសំខាន់ចំពោះទ្រង់ ។

សូមឲ្យយើងជឿ ទុកចិត្ត និ រស់នៅដោយត្រឹមត្រូវ ដើម្បីយើងនឹងយល់អំពីតម្លៃ និង សក្កានុពលពិតដ៏អស់កល្បជានិច្ចរបស់យើង ។ សូមឲ្យយើងស័ក្តិសមចំពោះពរជ័យដ៏មានតម្លៃទាំងឡាយរបស់ព្រះវរបិតាសួគ៌យើង ដែលរៀបចំប្រទានដល់យើង នេះគឺជាការអធិស្ឋានរបស់ខ្ញុំនៅក្នុងព្រះនាមនៃព្រះបុត្រាទ្រង់ ជាព្រះយេស៊ូវគ្រីស្ទ អាម៉ែន ។

កំណត់ចំណាំ

1. សូមមើល ម៉ូសេ 1:2 ។
2. ម៉ូសេ 1:10។
3. ម៉ូសេ 1:33 ។
4. សូមមើល Andrew Craig, « Astronomers count the stars,» BBC News, ថ្ងៃទី 22 ខែ កក្កដា ឆ្នាំ 2003, http://news.bbc.co.uk/2/hi/science/nature/3085885.stm ។
5. ម៉ូសេ 7:30 ។
6. ម៉ូសេ 4:11 ។
7. គោលលទ្ធិ និង សេចក្ដីសញ្ញា 18:10 ។
8. សូមមើល ម៉ូសេ 1:38--39 ។
9. William Knox, « Mortality,» នៅក្នុង James Dalton Morrison បានបោះពុម្ព *Masterpieces of Religious Verse* (ឆ្នាំ 1948) ទំព័រ 397 ។
10. គោលលទ្ធិ និង សេចក្ដីសញ្ញា 121:7 ។
11. នីហ្វៃទី 3 11:38 ។
12. ម៉ូសាយ 3:19 ។
13. លូកា 18:14; សូមមើល ខ 9--13 ផងដែរ ។
14. ម៉ូសាយ 2:17 ។
15. សូមមើល កិច្ចការ 10:38 ។
16. ម៉ាថាយ 18:4; សូមមើល ខ 1--3 ផងដែរ ។
17. គោលលទ្ធិ និង សេចក្ដីសញ្ញា 1:23 ។
18. គោលលទ្ធិ និង សេចក្ដីសញ្ញា 1:19 ។
19. កូរិនថូសទី 1 1:27។
20. សូមមើល ហេព្រើរ 13:5 ។
21. កូរិនថូសទី 1 2:9 ។